# ប្រវត្តិ និង គោលការណ៍
# នៃសិទ្ធិមនុស្ស

## ក. ប្រវត្តិនៃសិទ្ធិមនុស្ស

មូលដ្ឋាននៃសិទ្ធិមនុស្ស ដូចជាការគោរពជីវិតមនុស្ស និងសេចក្តីថ្លៃថ្នូររបស់មនុស្សអាចត្រូវបានរកឃើញភាគច្រើននៅក្នុងសាសនា ( មានជាអាទិ៍ នៅក្នុងពុទ្ធសាសនា សាសនាអ៊ីស្លាម សាសនាជ្វីស (Judaism) លទ្ធិហិណ្ឌូ និងលទ្ធិតាវ) ។ ការវិវត្តន៍នៃសិទ្ធិមនុស្ស មានឫសគល់ចេញមកពីការតស៊ូ ដើម្បីសេរីភាព និងសមភាពនៅគ្រប់ទីកន្លែងទាំងអស់នៅលើពិភពលោក ។

កាលបរិច្ឆេទខាងក្រោម បង្ហាញអំពីស្នាដៃសំខាន់ខ្លះៗនៃការតស៊ូនេះ[១] :

### ឆ្នាំ១៦៨៩: "Bill of Rights": សេចក្តីប្រកាសស្តីពីសិទ្ធិជាមូលដ្ឋាន ( ប្រទេសអង់គ្លេស)[២]

ជាលើកដំបូងនៅក្នុងប្រវត្តិមនុស្សជាតិ ការអះអាងដែលថាច្បាប់មានប្រភពមកពីអាទិទេព ឬពីស្តេចត្រូវបានបោះបង់ចោល ។ ច្បាប់នេះបានប្រកាសថា ស្តេចក៏ជាប្រធានមួយនៃវិធានច្បាប់ដូចប្រជាពលរដ្ឋដទៃ ទៀតដែរ ។ លើសពីនេះទៅទៀតវាបានចែងថា ស្តេចត្រូវតែគោរពអំណាចសភាដែលត្រូវបានបោះឆ្នោត ជ្រើសរើសឡើងដោយសេរីដោយប្រជាជន ។ "Bill of Rights" គឺជាសេចក្តីប្រកាសដំបូងបង្អស់ដែលបានហាមឃាត់ការដាក់ទណ្ឌកម្មដ៏ព្រៃផ្សៃ និងការកាត់ទោសដោយអយុត្តិធម៌ ។ វា (Bill of Rights) បានធានានូវគណៈវិនិច្ឆ័យតុលាការមិនលំអៀង និង ចៅក្រមឯករាជ្យ ។


Bill of Rights
Congress of the United States


### ឆ្នាំ១៧៧៦: សេចក្តីប្រកាសឯករាជ្យ ( ប្រទេសអាមេរិក)[៣]

យោងតាមសេចក្តីប្រកាសនេះ រដ្ឋាភិបាលត្រូវបានបង្កើតឡើងដោយការព្រមព្រៀងរបស់ប្រជាជនដើម្បីការពារសិទ្ធិ ។ សេចក្តីប្រកាសនេះបានបង្ហាញពីសិទ្ធិទាំងនោះក្នុងផ្នែកទី១ ដូចខាងក្រោម:

---

[១] ចំពោះពត៌មានពិស្តារអំពីប្រវត្តិសិទ្ធិមនុស្ស សូមមើល: Asbjorn Eide (១៩៩៨) ក្រោម www.rightreform.net/texts/eide.html
[២] មើល www.duhaime.org/uk-billr.htm
[៣] មើល www.yale.edu/lawweb/avalon/declare.htm

"តាមធម្មជាតិ មនុស្សគ្រប់រូបគឺមានសិទ្ធិសេរីភាព និងឯករាជ្យដោយស្មើភាពគ្នា ហើយមានសិទ្ធិផ្ទាល់ខ្លួនខ្លះ ... ដូចជា សិទ្ធិមានភាពសប្បាយរីករាយក្នុងជីវិត និងមានសេរីភាព ដោយមានលទ្ធភាពទទួល និងកាន់កាប់កម្មសិទ្ធិលើទ្រព្យសម្បត្តិ និងការស្វែងរក និងការទទួលបាននូវសុភមង្គល និងសុវត្ថិភាព ។"

នៅដំណាក់កាលនោះ សេចក្តីប្រកាសមិនបានពង្រីកវិសាលភាពសិទ្ធិមនុស្សទៅដល់មនុស្សគ្រប់រូបនៅឡើយទេ ។ វាគ្រាន់តែអនុវត្តចំពោះជនជាតិស្បែកសប៉ុណ្ណោះ តែមិនទាន់ដល់ជនជាតិស្បែកខ្មៅដែលត្រូវបានគេចាត់ទុកជាទាសករ ។

**ឆ្នាំ១៧៨៩: សេចក្តីប្រកាសស្តីពីសិទ្ធិមនុស្ស និងសិទ្ធិពលរដ្ឋ (ប្រទេសបារាំង)**[៤]

សេចក្តីប្រកាសនេះ មានលំនាំភាគច្រើនចេញពីសេចក្តីប្រកាសឯករាជ្យនៃសហរដ្ឋអាមេរិកឆ្នាំ១៧៧៦ ។ សេចក្តីប្រកាសសង្កត់ធ្ងន់អំពីសិទ្ធិធម្មជាតិ និងសិទ្ធិដែលមិនអាចផ្ទេរបាន រួមមានដូចជា សេរីភាព សិទ្ធិកម្មសិទ្ធិ សន្តិសុខ និងសិទ្ធិដើម្បីតស៊ូប្រឆាំងនឹងការគៀបសង្កត់ ។ ខ្លឹមសារនៃមាត្រាទី១នៃសេចក្តីប្រកាស បានទទួលស្គាល់ផងដែរនូវសមភាព ជាពិសេសសមភាពចំពោះមុខច្បាប់ និង យុត្តិធម៌ ។

មនុស្សគ្រប់រូបកើតមក មានសិទ្ធិសេរីភាព និងសមភាព ។

ទន្ទឹមនឹងនេះ សេចក្តីប្រកាសក៏បានអះអាងផងដែរអំពីគោលការណ៍នៃការបែងចែកអំណាច ។ ស្តេចល្វីសទី១៦ (Louis XVI) បានឱ្យសច្ចាប័នលើសេចក្តីប្រកាសនេះដោយស្ថិតនៅក្រោមការគៀបសង្កត់ពីសភា និងពីប្រជាជនដែលបានដើរដង្ហែរក្បួនឆ្ពោះទៅទីក្រុង **Versailles** ។

**ឆ្នាំ១៩៣៩-១៩៤៥:**

ជាភ័ព្វសំណាងអាក្រក់ មនុស្សជាតិត្រូវទទួលរងនូវអំពើអមនុស្សធម៌ក្នុងកំឡុងរបបផ្តាច់ការណាស៊ី (Nazi-Germany) និងជប៉ុនដែលបានចាប់ផ្តើមសង្គ្រាមលោកលើកទី២ដែលបង្កឱ្យមនុស្សជាង ៥០លាននាក់ ត្រូវស្លាប់ ។



**វាលពិឃាដនៅខេត្តសៀមរាប (១៩៧៥-១៩៧៩)**




**ការនិរទេសជនជាតិជីហ្វដ៏ធំមួយនៅទសវត្សទី៤០**

---
[៤] មើល www.elysee.fr/ang/instit/text1_htm

តាមរយៈបទពិសោធន៍ពិភពលោកបានដឹងថាៈ

> " ... ការទទួលស្គាល់នូវសេចក្តីថ្លៃថ្នូរផ្ទាល់ខ្លួន និងសិទ្ធិស្មើភាពគ្នា និងសិទ្ធិដែលមិនអាចផ្ទេរបានរបស់សមាសជិកនៃគ្រួសារមនុស្សជាតិ គឺជាមូលដ្ឋាននៃសេរីភាព យុត្តិធម៌ និងសន្តិភាពនៅលើ ពិភពលោក ... " ។
> (សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស)

## ឆ្នាំ១៩៤៨ៈ សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស (UDHR)[៥]

សេចក្តីប្រកាសនេះ ត្រូវបានអនុម័តជាឯកច្ឆន្ទនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨ ដោយអង្គការសហប្រជាជាតិ ។ មាត្រា៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជាបានយោងលើសេចក្តីប្រកាសនេះផងដែរ ។ សេចក្តីប្រកាសនេះ គឺជាសេចក្តីថ្លែងការណ៍ស្តីពីសិទ្ធិមនុស្សដែលត្រូវបានទទួលយកយ៉ាងទូលំទូលាយបំផុតនៅលើពិភពលោក ។ ខ្លឹមសារស្នូលរបស់សេចក្តីថ្លែងការណ៍ គឺតំលៃផ្ទាល់ខ្លួននៃមនុស្សជាតិម្នាក់ៗ ។ សេចក្តីប្រកាសនេះ ចែងនូវសិទ្ធិមួយចំនួនជាមូលដ្ឋានរបស់មនុស្សម្នាក់ៗ នៅលើពិភពលោក ដោយមិនគិតពីពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា គំនិតនយោបាយ ឬគំនិតផ្សេងៗ សញ្ជាតិឬដើមកំណើតសង្គម ទ្រព្យសម្បត្តិ កំណើតស្ថានភាពផ្សេងឡើយ ។ សេចក្តីប្រកាសបានបញ្ជាក់ថា រដ្ឋាភិបាលបានសន្យាថា មិនត្រឹមតែជួយគាំពារដល់សិទ្ធិមួយចំនួនរបស់ប្រជាពលរដ្ឋខ្លួនតែប៉ុណ្ណោះទេ ប៉ុន្តែក៏ជួយគាំពារប្រជាជននៃប្រទេសដទៃផងដែរ ។ នោះមានន័យថា ព្រំដែនរវាងជាតិ និងជាតិមិនមែនជារនាំងក្នុងការជួយអ្នកដទៃឱ្យទទួលបានសិទ្ធិរបស់ពួកគេនោះទេ ។

## ស្ថានភាពគតិយុត្តិនៃសេចក្តីថ្លែងការណ៍ ៈ

ទោះបីជា សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្សជាប្រភពគំនិតនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិភាគច្រើនក៏ដោយ វាមិនមែនជាឯកសារគតិយុត្តិដែលចងភ្ជាប់នោះទេ ។ សេចក្តីថ្លែងការណ៍ ផ្តល់អំណាចជាសកលដល់គំនិតសាធារណៈ និង ជួយដល់ការបកស្រាយ និងការស្វែងយល់អំពីវិធានសិទ្ធិមនុស្សក្នុងស្រុកផងដែរ ។ គោលការណ៍នៃសេចក្តីថ្លែងការណ៍ ត្រូវបានប្រែសំរួលទៅជាកំលាំងគតិយុត្តិក្នុងទំរង់ជាកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR មើលខាងក្រោម) និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សិទ្ធិសង្គម និងសិទ្ធិវប្បធម៌ (ICESCR មើលខាងក្រោម) ។ ប្រទេសទាំងឡាយ ដែលបានឱ្យសច្ចាប័នលើកតិកាសញ្ញាទាំងនេះបានសន្យាថានឹងបង្កើតឱ្យមានច្បាប់ក្នុងស្រុកដើម្បីការពារសិទ្ធិមនុស្សទាំងនេះ ។ ទោះជាយ៉ាងណាក៏ដោយ ប្រទេសជាងពាក់កណ្តាលនៅលើពិភពលោក មិនបានឱ្យសច្ចាប័នលើកតិកាសញ្ញាទាំងពីរខាងលើនេះទេ ។

ទោះបីជា UDHR ត្រូវបានអនុម័តក៏ដោយ ក៏មនុស្សជាតិបានទទួលរងនូវអំពើឃោឃៅ និងការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរដែលកើតឡើងក្នុងកំឡុងឆ្នាំបន្តបន្ទាប់មកនេះ ឧទាហរណ៍ដូចជា នៅទសវត្សទី៥០ និងទី៦០ ប្រទេសរុស្ស៊ី និងចិនដែលបានគំរាមកំហែង ចាប់ឃុំឃាំង និង សំលាប់មនុស្សជាង ១០០.០០០នាក់ ពីព្រោះតែការមានជំនឿនយោបាយខុសគ្នា ។

---

[៥] មើល www1.umn.edu/humanrts/instree/b1udhr.htm

## ឆ្នាំ១៩៦៦: កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR)[៦]

កតិកាសញ្ញានេះចូលជាធរមាននៅឆ្នាំ១៩៧៦ និងថែងកាន់តែស៊ីជំរៅអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលបានរៀបរាប់នៅក្នុង UDHR ហើយកតិកាសញ្ញានេះជាការចងភ្ជាប់គតិយុត្តិ ទៅក្នុងប្រទេសទាំងនោះ (រហូតមកដល់ឥឡូវមាន១៤៨ប្រទេស) ដែលបានឱ្យសច្ចាប័នលើកតិកាសញ្ញានេះ ។ ព្រះរាជាណាចក្រកម្ពុជាបានឱ្យសច្ចាប័ននៅថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩២។

**ICCPR** រួមបញ្ចូលទាំង (មើលមាត្រា៦ ដល់ មាត្រា២៧):

- សិទ្ធិរស់រានមានជីវិត
- សិទ្ធិរួចផុតពីទណ្ឌកម្ម ឬទាសភាព
- សិទ្ធិមានសេរីភាព និងសន្តិសុខ
- សិទ្ធិសេរីភាពក្នុងការដើរហើរ បង្កើតសមាគម ខាងសាសនា និងក្នុងការបញ្ចេញមតិយោបល់
- សិទ្ធិស្មើគ្នាចំពោះមុខច្បាប់
- សិទ្ធិមានជីវិតផ្ទាល់ខ្លួន
- សិទ្ធិស្មើគ្នាក្នុងការរៀបអាពាហ៍ពិពាហ៍ និង
- សិទ្ធិក្នុងការគោរពតាមទំនៀមទំលាប់វប្បធម៌ខ្លួន

**ICCPR** ផ្តល់នូវយន្តការត្រួតពិនិត្យជាបន្តបន្ទាប់ដូចខាងក្រោម:

- កតិកាសញ្ញាបង្កើតគណៈកម្មាធិការសិទ្ធិមនុស្សមួយ (HRC) ដែលមានសមាជិក ១៨នាក់ (មាត្រា១) ដើម្បីត្រួតពិនិត្យតាមដានការអនុវត្តន៍កតិកាសញ្ញាដោយធ្វើការពិនិត្យពិច័យលើរបាយការណ៍ជាប្រចាំរបស់រដ្ឋភាគី(មាត្រា៤០)
- ក្នុងស្ថានភាពខ្លះ HRC អាចពិនិត្យលើបណ្តឹងដែលទទួលបានពីប្រទេសផ្សេងទៀត (មាត្រា៤១) ដែលបានឱ្យសច្ចាប័នលើកតិកាសញ្ញា ។ រហូតមកដល់បច្ចុប្បន្ន ករណីនេះពុំទាន់កើតមាននៅឡើយទេ ។
- បុគ្គលទាំងឡាយដែលជឿជាក់ថា សិទ្ធិរបស់ពួកគេស្ថិតក្នុងក្របខ័ណ្ឌកតិកាសញ្ញា ត្រូវបានរំលោភបំពាន អាចប្តឹងមក HRC (មាត្រា១ នៃពិធីសារជំរើសនៃICCPR[៧] ឆ្នាំ១៩៦៦) ។ រហូតមកដល់ពេលនេះ បុគ្គល៣៤៥នាក់ហើយដែលបានប្រើលទ្ធភាពគតិយុត្តិនេះ ។ បណ្តឹងចំនួន ១៨២បណ្តឹង កំពុងតែត្រូវធ្វើការសំរេច ។
- HRC បង្កើតនូវមតិទូទៅផងដែរដែលអាចជួយស្រាយបំភ្លឺអ្វីដែលប្រទេសទាំងនោះត្រូវធ្វើដើម្បីឱ្យស្របនឹង ICCPR ។

[៦] www1.umn.edu/humanrts/instress/b3ccpr.htm

[7] www1.umn.edu/humanrts/instree/b4ccprp1.htm

## ឆ្នាំ១៩៦៦: កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សិទ្ធិសង្គម និងសិទ្ធិវប្បធម៌ (CESCR)[៨]

កតិកាសញ្ញានេះចូលជាធរមានផងដែរនៅឆ្នាំ១៩៧៦ ។ វាផ្តល់នូវសេចក្តីពិស្តារអំពីសិទ្ធិសេដ្ឋកិច្ច សិទ្ធិសង្គម និងសិទ្ធិវប្បធម៌ ដែលរៀបរាប់ដំបូងនៅក្នុង (UDHR) ។ វាជាចំណងគតិយុត្តិចំពោះប្រទេសទាំងឡាយណាដែលបានឱ្យសច្ចាបន័ ។ ព្រះរាជាណាចក្រកម្ពុជាបានឱ្យសច្ចាប័នលើកតិកាសញ្ញានេះនៅថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩២ ។

**ICESCR** រួមបញ្ចូលនូវ :

- សិទ្ធិការងារ មានស្ថានភាពការងារត្រឹមត្រូវ និងល្អប្រសើរ
- សិទ្ធិបង្កើត និងចូលរួមក្នុងសហជីព
- សិទ្ធិមានជីវិតគ្រួសារ
- សិទ្ធិមានកំរិតជីវភាពរស់នៅគ្រប់គ្រាន់
- សិទ្ធិមានកំរិតសុខភាពខ្ពស់បំផុតដែលអាចធ្វើបាន
- សិទ្ធិទទួលការអប់រំ
- សិទ្ធិចូលរួមក្នុងសកម្មភាពវប្បធម៌

យ៉ាងណាមិញ កតិកាសញ្ញានេះមានយន្តការត្រួតពិនិត្យតែមួយគត់: ការរាយការណ៍អំពីកាតព្វកិច្ចរបស់រដ្ឋភាគីនីមួយៗ (មាត្រា១៦) ។ គឺធានាធ្វើយ៉ាងណាឱ្យរដ្ឋភាគីត្រួតពិនិត្យឱ្យបានជាប់ជាប្រចាំពីសភាពការណ៍ដែលទាក់ទិនទៅនឹងការគោរពសិទ្ធិនីមួយៗ និង ពីវិសាលភាពនៃសិទ្ធិទាំងនោះថា តើពលរដ្ឋគ្រប់រូបានទទួលដែរឬទេ នៅក្នុងប្រទេសរបស់ពួកគេ ឬនៅក្រោមយុត្តាធិការរបស់ពួកគេ ។

UDHR ICCPR និង ICESCR ត្រូវបានទទួលស្គាល់ដូចជាកំរងសិទ្ធិអន្តរជាតិ ( **International Bill of Rights**) ។

ចាំបាច់ត្រូវលើកពីអនុសញ្ញាសំខាន់ៗបួនទៀតស្តីពីសិទ្ធិមនុស្ស ដោយសារអនុសញ្ញាទាំងនោះ (រួមទាំងកំរងសិទ្ធិអន្តរជាតិ) បង្កើតនូវខ្លឹមសារនៃសន្ធិសញ្ញាអន្តរជាតិ :

## ឆ្នាំ១៩៦៩ : កតិកាសញ្ញាអន្តរជាតិស្តីពីការបំបាត់សព្វបែបយ៉ាងនៃការប្រកាន់ពូជសាសន៍ (CERD)[៩]

នៅក្នុងខ្លឹមសារនៃមាត្រា៤អនុសញ្ញាតំរូវឱ្យរដ្ឋភាគីធ្វើការផ្តន្ទាទោសទៅលើការប្រតិបត្តិខុសឆ្គង ៤យ៉ាង:

- ការផ្សព្វផ្សាយគំនិតអំពីឧត្តមភាព ឬការស្អប់ខ្ពើមពូជសាសន៍
- ការញុះញង់ឱ្យមានការស្អប់ខ្ពើមពូជសាសន៍
- អំពើហឹង្សាប្រឆាំងនឹងជាតិសាសន៍ ឬអំបូរណាមួយនៃពណ៌សម្បុរ ឬពូជអំបូរដើមណាមួយផ្សេងទៀត និង
- ការញុះញង់ឱ្យមានអំពើទាំងនោះ ។

ដើម្បីបំពេញនូវកាតព្វកិច្ចទាំងនេះ រដ្ឋភាគីមិនត្រឹមតែត្រូវអនុម័តបទបញ្ញត្តិឱ្យបានសមស្របនោះទេ ប៉ុន្តែត្រូវតែធានាផងដែរនូវប្រសិទ្ធិភាពនៃការអនុវត្តន៍ ។

---

[៨] មើល www1.umn.edu/humanrts/instree/b2esc.htm

[៩] មើល www1.umn.edu/humanrts/instree/e1cedaw.htm

ការហាមឃាត់ផ្សព្វផ្សាយគំនិតពីឧត្តមភាព ឬការស្អប់ខ្ពើមពូជសាសន៍ មានលក្ខណៈស្របជាមួយនឹងសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងសារពត៌មាន ។ សិទ្ធិនេះត្រូវដាក់បញ្ចូលក្នុងមាត្រា១៩ នៃ UDHR និងត្រូវបានចែងផងក្នុងមាត្រា៥ នៃ CERD ។

យន្តការត្រួតពិនិត្យៈ ត្រូវបានចែងនៅក្នុងមាត្រា៨ ដល់មាត្រា១១ នៃ CERD ។

## ឆ្នាំ១៩៧៩: អនុសញ្ញាស្តីពីការបំបាត់រាល់រូបភាពនៃការរើសអើងប្រឆាំងនារីភេទ (CEDAW)[១០]

អនុសញ្ញានេះចូលជាធរមាននៅឆ្នាំ១៩៨១ ។ អនុសញ្ញានេះ គឺជាសន្ធិសញ្ញាអន្តរជាតិតែមួយគត់ដែលកំណត់ពីសិទ្ធិរបស់ស្ត្រី និង គោលដៅវប្បធម៌ និងប្រពៃណី ថាជាកំលាំងជំរុញតួនាទីយេនឌ័ (Gender) និងទំនាក់ទំនងគ្រួសារ ។ អនុសញ្ញានេះជាមូលដ្ឋានកំណត់នូវសមភាពរវាងបុរស និងនារី តាមរយៈការធានាឱ្យស្ត្រីមានសិទ្ធិ និងឱកាសស្មើគ្នាចូលរួមនៅក្នុងនយោបាយ និងសាធារណៈ(រួមទាំងសិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះបោះឆ្នោត) ក៏ដូចជាក្នុងការអប់រំសុខភាព និងការបំពេញការងារ (មាត្រា១) ។ ព្រមជាមួយគ្នានេះដែរ មានការប្រកាន់យកនូវវិធានការដើម្បីធ្វើឱ្យមានភាពស្មើគ្នារវាងបុរស និងនារី រហូតទទួលបានសមភាព (មាត្រា៤) ។

ការទទួលយកនូវអនុសញ្ញានេះ រដ្ឋភាគីមានកាតព្វកិច្ចត្រូវអនុវត្តទៅតាមខ្លឹមសារនៃអនុសញ្ញា និងត្រូវប្រកាន់យកវិធានការណ៍មួយចំនួន ដើម្បីបញ្ចប់នូវការរើសអើងប្រឆាំងនឹងស្ត្រីតាមគ្រប់រូបភាពទាំងអស់រួមទាំង :

- បញ្ចូលគោលការណ៍សមភាពរវាងបុរស និងស្ត្រី នៅក្នុងប្រព័ន្ធគតិយុត្តិ លុបបំបាត់ចោលនូវច្បាប់ដែលមានលក្ខណៈរើសអើងទាំងអស់ និងអនុម័តនូវច្បាប់ទាំងឡាយណាដែលហាមឃាត់ដល់ការរើសអើងប្រឆាំងនឹងនារីភេទ
- បង្កើតតុលាការ និងស្ថាប័នសាធារណៈនានា ដើម្បីធានាឱ្យមានប្រសិទ្ធិភាពក្នុងការការពារប្រឆាំងនឹងការរើសអើងនេះ និង
- ធានាឱ្យមានការលុបបំបាត់នូវរាល់អំពើរើសអើងប្រឆាំងនារីភេទ ដោយមនុស្ស អង្គការ ឬដោយសហគ្រាស (មាត្រា១៦: ឧ. ការរើសអើងដោយសង្គម ដោយសារធ្លាប់ធ្វើ ការលែងលះ ឬមេម៉ាយ) ។

យន្តការត្រួតពិនិត្យៈ យ៉ាងហោចណាស់រៀងរាល់៤ឆ្នាំម្តង រដ្ឋភាគីត្រូវធ្វើរបាយការណ៍ជាតិស្តីអំពីវិធានការណ៍ដែលបានប្រកាន់យកដើម្បីបំពេញទៅតាមកាតព្វកិច្ចដែលមានចែងក្នុងសន្ធិសញ្ញា ។ បុគ្គលឯកជនមិនអាចប្តឹងបានទេ ។

## ឆ្នាំ១៩៨៤: អនុសញ្ញាប្រឆាំងនឹងទារុណកម្ម (CAT)[១១]

ដើម្បីបង្កើនប្រសិទ្ធិភាពដល់ការតស៊ូប្រឆាំងនឹងទារុណ្ឌកម្ម និង ការបំពានឃោឃៅ អមនុស្សធម៌ ឬ ថោកទាបដែលកើតមានឡើងនៅពាសពេញពិភពលោកនោះ **CAT** បានប្រកាសនៅក្នុងមាត្រា២របស់ខ្លួនថា :

[១០] www1.umn.edu/humanrts/instree/e1cedaw.htm
[១១] មើល www1.umn.edu/humanrts/instree/h1dpast.htm

" ... ទោះក្នុងករណីណាក៏ដោយ ក្នុងស្ថានភាពមានសង្គ្រាម ឬត្រូវរងគំរាមដោយសង្គ្រាម អស្ថេរភាពនយោបាយក្នុងស្រុក ឬការប្រកាសអាសន្នសាធារណៈបែបណាក៏ដោយមិនអាចលើកឡើងជាលេសដើម្បីធ្វើទារុណកម្មឡើយ ..."

យន្តការត្រួតពិនិត្យៈ ដែលហៅថា "អ្នករាយការណ៍ពិសេសប្រឆាំងនឹងទារុណកម្ម" ដែលមានកាតព្វកិច្ចត្រួតពិនិត្យតាមដានកិច្ចប្រឹងប្រែងតស៊ូប្រឆាំងនឹងទារុណកម្មនៅក្នុងគ្រប់ប្រទេសទាំងអស់នៅលើពិភពលោក ។ អ្នករាយ-ការណ៍អាចធ្វើទស្សនកិច្ចនៅប្រទេសណាដែលគាត់ត្រូវបានគេអញ្ជើញឱ្យទៅ ដើម្បីពិនិត្យដំបូងអំពីស្ថានភាព និងផ្តល់អនុសាសន៍ទៅអាជ្ញាធរ ។ នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០២ ពិធីសារជំរើសទៅនឹងអនុសញ្ញារបស់អង្គការសហប្រជាជាតិប្រឆាំងនឹងទារុណកម្ម ត្រូវបានអនុម័តដោយមហាសន្និតអង្គការសហប្រជាជាតិ ។ ពិធីសារនេះបង្កើតនូវប្រព័ន្ធមួយនៃការធ្វើទស្សនកិច្ចយ៉ាងទៀងទាត់ដោយស្ថាប័នជាតិ និងអន្តរជាតិឯករាជ្យនៅកន្លែង ឃុំឃាំង ដើម្បីបង្ការការធ្វើទារុណកម្ម និង អំពើមិនគប្បីដែលមានគ្រប់រូបភាព ។

**ឆ្នាំ១៩៨៩: អនុសញ្ញាស្តីពីសិទ្ធិកុមារ (CRC)**[១២]

អនុសញ្ញាស្តីពីសិទ្ធិកុមារ គឺជាសន្ធិសញ្ញាមួយដែលគេឱ្យសច្ចាប័នច្រើនជាងគេបំផុតនៅលើពិភពលោក ( មានតែប្រទេសសូម៉ាលី និងសហរដ្ឋអាមេរិកប៉ុណ្ណោះដែលមិនបានឱ្យសច្ចាប័ន ) ។

អនុសញ្ញានេះ ផ្តល់ឱ្យកុមារនៅលើ ពិភពលោកនូវ :

- សិទ្ធិរស់រានមានជីវិត
- សិទ្ធិសេរីភាព
- សិទ្ធិទទួលបាននូវការអប់រំ និង
- សិទ្ធិទទួលបាននូវការថែរក្សាផ្នែកសុខភាព

អនុសញ្ញានេះ ផ្តល់នូវការការពារដល់កុមារ :

- ក្នុងជំលោះប្រដាប់អាវុធ
- ពីការរើសអើង
- ពីទារុណកម្ម ឬការដាក់ទណ្ឌកម្ម ឬប្រព្រឹត្តិអំពើឃោឃៅ អមនុស្សធម៌ ឬថោកទាប
- នៅក្នុងប្រព័ន្ធតុលាការ និង
- ពីការធ្វើអាជីវកម្មកេងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ច

បន្ទាប់មកមានសន្និសិទសំខាន់ៗមួយចំនួនៈ

**ឆ្នាំ១៩៩៣:** នៅក្នុង "សន្និសិទពិភពលោកមួយស្តីពីសិទ្ធិមនុស្ស"[១៣] **នាទីក្រុង វីយែន នៃប្រទេសអូទ្រីស**

រដ្ឋចំនួន ១៧១ ដែលតំណាងឱ្យប្រជាជនជាង៩៩% នៅលើពិភពលោកបានអះអាងជាថ្មីនូវការគាំទ្ររបស់ពួកគេចំពោះសិទ្ធិមនុស្ស ។

[១២] មើល www1.umn.edu/humanrts/instree/k1drc.htm
[១៣] មើល www1.umn.edu/humnarts/instree/l1viedec.html

**ឆ្នាំ១៩៩៥:** នៅឯ "សន្និសិទពិភពលោកលើកទី៤ ស្តីពីសិទ្ធិស្ត្រី"[១៤] **នាទីក្រុងប៉េកាំងនៃប្រទេសចិន** សហគមន៍ពិភពលោកបានទទួលស្គាល់ថា នៅក្នុងទសវត្សរកន្លងមកនេះ ស្ថានភាពស្ត្រីបានឆ្ពោះទៅមុខទៅរកការគោរពសិទ្ធិជាចំបងខ្លះហើយ ប៉ុន្តែនៅមានវិសមភាពរវាងបុរស និងនារីនៅឡើយ ហើយនៅតែមានឧបសគ្គធំៗ ដោយបន្សល់នូវផលវិបាកធ្ងន់ធ្ងរជាច្រើនដល់ ភាពសុខដុមរបស់មនុស្សទាំងអស់ ។

**ឆ្នាំ២០០១:** នាប្រទេសដុយបង់ (**Durban**)[១៥] **នៅអាហ្វ្រិកខាងត្បូង** "សន្និសិទពិភពលោកប្រឆាំងនឹងការប្រកាន់ពូជសាសន៍" បានសំដែងនូវការព្រួយបារម្ភថា ទោះបីមានការខិតខំប្រឹងប្រែងរបស់សហគមន៍អន្តរជាតិទិសដៅចំបងដើម្បីបំបាត់ការប្រកាន់ពូជសាសន៍នៅមិនទាន់សំរេចនៅឡើយ ហើយនៅពេលបច្ចុប្បន្នមនុស្សជាតិរាប់មិនអស់នៅតែរងគ្រោះ ពីការប្រកាន់ពូជសាសន៍ ការរើសអើងពូជសាសន៍ ការស្អប់ជនបរទេស និង ការមិនចេះអត់អោន ។

ក្រៅពីអនុសញ្ញា និងសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិ សន្ធិសញ្ញាស្តីពីសិទ្ធិមនុស្ស ហើយនិងប្រព័ន្ធសិទ្ធិមនុស្សថ្នាក់តំបន់ត្រូវបានបង្កើតឡើងនៅទ្វីបអាមេរិក អាហ្វ្រិក និងអឺរ៉ុប ដើម្បីអះអាងអំពីការរួបរួមរបស់ពួកគេក្នុងការគោរពសិទ្ធិមនុស្ស និងដើម្បីផ្តល់ឱ្យប្រជាពលរដ្ឋរបស់ពួកគេនូវការការពារសិទ្ធិមនុស្សថ្នាក់តំបន់ ។

**ឆ្នាំ១៩៥០:** អនុសញ្ញាអឺរ៉ុបដើម្បីការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន[១៦]

**ឆ្នាំ១៩៧៨:** អនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស[១៧]

**ឆ្នាំ១៩៨១:** ធម្មនុញ្ញអាហ្វ្រិក (ប្រទេសបង់ស៊ុល) ស្តីពីសិទ្ធិមនុស្ស និងសិទ្ធិប្រជាជន[១៨]

**ឆ្នាំ២០០០:** គណៈកម្មការសិទ្ធិមនុស្សនៃប្រទេសហ្វីលីពីន បានប្រកាសអំពី "ពង្រាងសេចក្តីថ្លែងការណ៍ស្តីពីសិទ្ធិមនុស្ស និងសិទ្ធិប្រជាជននៃប្រទេសហ្វីលីពីន" ដែលអាចជួយផ្តល់ជាគំរោងសេចក្តីប្រកាសស្តីពីសិទ្ធិមនុស្សសំរាប់ប្រទេសជាសមាជិកអាស៊ាន[១៩] ។

## ខ. គោលការណ៍សិទ្ធិមនុស្ស

### ១. អ្វីទៅជាសិទ្ធិមនុស្ស?

សិទ្ធិមនុស្សគឺជា:

- កំរិតស្តង់ដារជាមូលដ្ឋានដែលមនុស្សត្រូវការដើម្បីរស់នៅក្នុងភាពថ្លៃថ្នូរជាមនុស្ស
- មូលដ្ឋានគ្រឹះនៃសេរីភាព យុត្តិធម៌ និងសន្តិភាព

[១៤] មើល www1.umn.edu/humanrts/instree/bejingdec/htm
[១៥] មើល www1.umn.edu/humanrts/instree/wcardeclaration.html
[១៦] មើល www1.umn.edu/humanrts/instree/z17euroco.html
[១៧] មើល www1.umn.edu/humanrts/oasinstr/zoas3zcon.htm
[១៨] មើល www1.umn.edu/humanrts/instree/z1afchar.htm
[១៩] មើល www.codewan.com.ph/hrnow/body/htm

- ការធានាការអភិវឌ្ឍន៍ពេញលេញមួយដល់បុគ្គល និងសហគមន៍
- វិធានមួយសំរាប់រដ្ឋាភិបាលអំពីអ្វីដែលត្រូវធ្វើ និងអ្វីដែលមិនត្រូវធ្វើ ដើម្បីជាការគោរពដល់សិទ្ធិរបស់ប្រជាពលរដ្ឋ ។
- សិទ្ធិដែលត្រូវបានប្រកាសនៅក្នុងសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស (UDHR)

## ២. ចរិតលក្ខណៈនៃសិទ្ធិមនុស្ស

សិទ្ធិមនុស្សមានលក្ខណៈ

### ២.១. “ជាធម្មជាតិរបស់បុគ្គលម្នាក់ៗ”

សិទ្ធិមនុស្ស មិនអាចត្រូវបានទិញ រកបាន ឬធ្វើមរតកបានឡើយ ។ ជាធម្មតា សិទ្ធិមនុស្សជាកម្មសិទ្ធិរបស់មនុស្សតាំងពីកំណើត (សិទ្ធិដែលមានមកពីកំណើត) ពីព្រោះពួកគេជាមនុស្ស ។

### ២.២. “សកល”

សិទ្ធិមនុស្សទាំងអស់ មានលក្ខណៈដូចៗគ្នាសំរាប់មនុស្សទាំងអស់នៅលើពិភពលោក ដោយមិនប្រកាន់អំពីជាតិសាសន៍ ភេទ សាសនា គំនិតនយោបាយ ឬគំនិតផ្សេងៗ សញ្ជាតិឬដើមកំណើតសង្គមឡើយ ។ យើងទាំងអស់គ្នាកើតមកដោយសេរី និងស្មើភាព នៅក្នុងសេចក្តីថ្លៃថ្នូរ និងសិទ្ធិ ។

### ២.៣. “មិនអាចបំបែកបាន”

មនុស្សរស់នៅក្នុងសេចក្តីថ្លៃថ្នូរ ។ សិទ្ធិមនុស្សទាំងអស់ ត្រូវរួមមានសេរីភាព សន្តិសុខ និងកិត្តិយសរបស់ខ្លួនប្រចាំថ្ងៃសមរម្យ ។

### ២.៤.“មិនអាចលក់ ឬផ្ទេរបាន”

សិទ្ធិមនុស្សទាំងអស់ មិនអាចត្រូវបានដកហូត ឬលក់ (ឧទាហរណ៍: ការសន្យាថាមិនទៅធ្វើបាតុកម្មជាអំពើមិនស្របច្បាប់) បានទេ ។ គ្មាននរណាម្នាក់មានសិទ្ធិដកហូតសិទ្ធិមនុស្សរបស់អ្នកដទៃដោយមូលហេតុណាមួយបានឡើយ ។ មនុស្សនៅតែមានសិទ្ធិមនុស្ស ទោះបីនៅពេលដែលច្បាប់នៃប្រទេសរបស់ពួកគេមិនបានទទួលស្គាល់សិទ្ធិទាំងនោះ ឬនៅពេលដែលច្បាប់ទាំងនោះរំលោភបំពានសិទ្ធិមនុស្សទាំងនោះក៏ដោយ ។

ឧ. នៅពេលដែលទាសភាពកើតមានឡើង ទាសករនៅតែមានសិទ្ធិរបស់ខ្លួន ទោះបីជាសិទ្ធិទាំងនោះត្រូវបានរំលោភបំពានក៏ដោយ ។

## ៣. ប្រភេទនៃសិទ្ធិ

សិទ្ធិត្រូវបានចែកចេញជា ៣ ប្រភេទ :

## ៣.១. សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (សិទ្ធិក្នុង"ជំណាក់កាលទី១")

"សិទ្ធិទាំងនោះសំដៅលក្ខណៈជាសេរីភាព " រួមទាំងសិទ្ធិរស់រានមានជីវិត សិទ្ធិសេរីភាព និង សិទ្ធិមានសន្តិសុខផ្ទាល់ខ្លួន(មានសេរីភាពរួចផុតពីការដាក់ទណ្ឌកម្ម និងពីទាសភាព) សិទ្ធិចូលរួមក្នុង ការងារនយោបាយ (សេរីភាពក្នុងការបញ្ចេញមតិ សេរីភាពខាងសារពត៌មាន ខាងការបញ្ចេញគំនិត ខាងវិចារណញ្ញាណ និងខាងសាសនា) សេរីភាពក្នុងការបង្កើតសមាគម និងក្នុងការប្រជុំ ។

## ៣.២. សិទ្ធិសេដ្ឋកិច្ច និងសង្គម (សិទ្ធិក្នុង"ជំណាក់កាលទី២")

"សិទ្ធិទាំងនេះសំដៅលក្ខណៈជាសេរីភាព" ។ ឧទាហរណ៍ដូចជា សិទ្ធិមានការងារធ្វើ សិទ្ធិទទួល បានការអប់រំ សិទ្ធិទទួលបានជីវភាពរស់នៅសមរម្យ សិទ្ធិមានអាហារគ្រប់គ្រាន់ សិទ្ធិមានជំរក និង សិទ្ធិមានការយកចិត្តទុកដាក់ផ្នែកសុខភាព ។

## ៣.៣. សិទ្ធិមានបរិស្ថាន សិទ្ធិវប្បធម៌ និងសិទ្ធិអភិវឌ្ឍន៍ (សិទ្ធិក្នុង"ជំណាក់ទី៣")

វារួមបញ្ចូលទាំងសិទ្ធិរស់នៅក្នុងបរិស្ថានមួយបរិសុទ្ធ និងត្រូវបានការពារពីការបំផ្លិចបំផ្លាញ និង សិទ្ធិក្នុងការអភិវឌ្ឍន៍វប្បធម៌ នយោបាយ និងសេដ្ឋកិច្ច ។

## ? សំនួរសិក្សាទី ១

ចូរអានសេចក្តីថ្លែងការណ៍ស្តីពីសិទ្ធិមនុស្ស (ឆ្នាំ១៧៨៩) ។
តើមាត្រាណាខ្លះនៃសេចក្តីថ្លែងការណ៍នេះចង្អុលពី "ការនិយាយស្តីដោយសេរី"?

## ? សំនួរសិក្សាទី ២

មេដឹកនាំនៃប្រទេសនៅអាស៊ីមួយចំនួន (ដូចជានៅប្រទេសសឹង្ហបុរី និងម៉ាឡេស៊ី) ទាមទារថា: "តំលៃអាស៊ី" (មានន័យថាជាការគោរពចំពោះអាជ្ញាធរ និងការជឿជាក់ថា ក្រុមមានសារៈសំខាន់ជាងបុគ្គលឯកជន) មានតំលៃលើសលុបលើសិទ្ធិមនុស្ស ។ ពួកគេនិយាយថា ពួកគេអាចអនុគ្រោះឱ្យមានសេរីភាពខាងសេដ្ឋកិច្ច (ដូចជា សេរីភាពខាងកម្មសិទ្ធិ និងសេរីភាពក្នុងការប្រកបអាជីវកម្ម) ប៉ុន្តែមិនត្រូវដាក់ចេញនូវសេរីភាពបុគ្គលដទៃទៀតទេ (ដូចជា សេរីភាពក្នុងការនិយាយស្តី) នៅក្នុងពេលជាមួយគ្នានោះទេ ពីព្រោះថាសេរីភាពបុគ្គលទាំងនេះគឺជាឧបសគ្គចំពោះការត្រួតពិនិត្យរបស់រដ្ឋ និងការរីកលូតលាស់នៃសេដ្ឋកិច្ច ។

តើអ្នកយល់ស្រប ឬមិនយល់ស្របចំពោះគំនិតនោះ? ចូរពន្យល់ការយល់ឃើញរបស់អ្នកនៅទីនេះ!

## ? សំនួរសិក្សាទី ៣

សូមអានកតិកាសញ្ញា និងសេចក្តីប្រកាសនានាដែលហៅថា "កំរងសិទ្ធិអន្តរជាតិ" (International Bill of Rights) ។
តើមាត្រាណាខ្លះដែលទាក់ទងនឹង "សិទ្ធិបោះឆ្នោត"?